ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# គោលការណ៍ប្រតិបត្តិស្តង់ដារ (SOP)
# សម្រាប់ដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
# (អ.ប.វ.) ឡើងវិញក្នុងបរិបទកូវីដ-១៩

ខែតុលា ឆ្នាំ២០២១

## អារម្ភកថា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បច្ចុប្បន្នមានគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ចំនួន ១៩៩ ក្នុងនោះ គ្រឹះស្ថាន អ.ប.វ. សាធារណៈ ចំនួន ៣៨ និងឯកជន អង្គការ/សមាគម ចំនួន ១៦១ ដែលមានសិក្ខាកាម សិស្ស និស្សិត ប្រមាណជាង ៦០ ០០០នាក់ បានបញ្ចប់ការសិក្សានិងចូលទៅក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំ។ កន្លងមក រាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍អនុញ្ញាតបើកឡើងវិញនូវរោងជាង បន្ទប់ពិសោធន៍ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព ការប្រឡងបញ្ចប់ និងការពារសារណា ឬនិក្ខេបបទបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថាន អ.ប.វ. ក្រោមឱវាទក្រសួង តាមរយៈលិខិតលេខ ៦៧៧ សជណ.អវ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ចាប់តាំងពីព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ មក គ្រឹះស្ថាន អ.ប.វ. ទាំងអស់ត្រូវបានផ្អាកដំណើរការសិក្សា និងអនុវត្តផ្ទាល់ ដើម្បីចូលរួមអនុវត្តនូវវិធានការនានារបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង ការបង្ការ និងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។

ក្នុងបរិបទកូវីដ-១៩ នេះ គ្រឹះស្ថាន អ.ប.វ. បានផ្តល់ការបណ្តុះបណ្តាលនៅគ្រប់កម្រិតសិក្សា ទាំងរយៈពេលខ្លី និងវែង ពីចម្ងាយ ឬតាមអនឡាញ ព្រមទាំងបានឆ្លៀតឱកាសបំពាក់ឧបករណ៍ សម្ភារ បរិក្ខារមូលដ្ឋានបច្ចេកវិទ្យា ក៏ដូចជាការពង្រឹងសមត្ថភាពគ្រូបច្ចេកទេស ការកែលម្អ និងអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាល ដើម្បីគាំទ្រដល់កម្មវិធីបណ្តុះបណ្តាលនៅពេលបើកដំណើរការឡើងវិញ។ គុណភាពនៃការបណ្តុះបណ្តាលពីចម្ងាយ ឬតាមអនឡាញជាទូទៅ គឺនៅមានកម្រិត ដោយសារតែសិក្ខាកាម សិស្ស និស្សិត ពុំបានអនុវត្តជាក់ស្តែងនៅតាមរោងជាង បន្ទប់ពិសោធន៍ ដែលជាតម្រូវការចាំបាច់បំផុតនៅក្នុងប្រព័ន្ធ អ.ប.វ.។

ការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ គឺមានភាពចាំបាច់ណាស់ ដើម្បីធានាបាននូវការបណ្តុះបណ្តាលប្រកបដោយគុណភាព និងប្រសិទ្ធភាព នៃកម្លាំងពលកម្មជំនាញ ឆ្លើយតបតម្រូវការទីផ្សារការងារ។ បន្ថែមពីនេះ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក៏ជាឧបករណ៍នយោបាយរបស់រាជរដ្ឋាភិបាលដ៏សំខាន់ក្នុងការស្តារសេដ្ឋកិច្ចជាតិឡើងវិញបន្ទាប់ពីការរងផលប៉ះពាល់នៃជំងឺកូវីដ-១៩។ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការបង្ការ ការទប់ស្កាត់ និងការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតាមគ្រឹះស្ថាន អ.ប.វ. ក្រសួងបានរៀបចំនូវ **គោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ** ដោយមានការកំណត់យន្តការច្បាស់លាស់ក្នុងការគ្រប់គ្រង លក្ខណវិនិច្ឆ័យនៃការបើក និងការផ្អាកដំណើរការ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន ភារកិច្ចរបស់គ្រឹះស្ថាន អ.ប.វ. និងសិក្ខាកាម សិស្ស និស្សិត ការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធ ការវាយតម្លៃហានិភ័យ និងប្រព័ន្ធរាយការណ៍ សំដៅធានាបាននូវសុវត្ថិភាពសុខភាពសាធារណៈសម្រាប់គណៈគ្រប់គ្រង បុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស ព្រមទាំងសិក្ខាកាម សិស្ស និស្សិត ស្របតាមគន្លងប្រក្រតីភាពថ្មី។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត មន្ទីរសុខាភិបាលរាជធានី ខេត្ត អាជ្ញាធរដែនដី គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សាស្ត្រាចារ្យ គ្រូបច្ចេកទេស អាណាព្យាបាល សិក្ខាកាម សិស្ស និស្សិត និងគ្រប់ភាគីពាក់ព័ន្ធនឹងចូលរួមអនុវត្តតាមខ្លឹមសារនៃគោលការណ៍ប្រតិបត្តិស្តង់ដានេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

ថ្ងៃ សុក្រ ២រោច ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**គោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ដំណើរការគ្រឹះស្ថានអប់រំ**
**បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ឡើងវិញក្នុងបរិបទកូវីដ-១៩**

## ១. ការរៀបចំយន្តការដំណើរការ និងការគ្រប់គ្រង

- ត្រូវរៀបចំបង្កើតគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ ដោយកំណត់សមាសភាព និងតួនាទីភារកិច្ចឱ្យបានច្បាស់លាស់
- ត្រូវអនុវត្តសេចក្តីណែនាំ និងវិធានការនានារបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាល
- ត្រូវលើកកម្ពស់ការអនុវត្តវិធានការ និងសេចក្តីណែនាំនានាស្តីពីការលើកកម្ពស់សុខភាព ការបង្ការជំងឺ ឬការបង្ការគ្រោះថ្នាក់នានាដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដាក់ចេញនាពេលកន្លងមកប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់
- ត្រូវរៀបចំយន្តការចាំបាច់នានាផ្សេងទៀតតាមការណែនាំរបស់រាជរដ្ឋាភិបាល
- ត្រូវរៀបចំក្រុមការងារទទួលរបាយការណ៍តេស្តកូវីដ-១៩ តាមនីតិវិធីជាធរមាន។

## ២. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅតាមគ្រឹះស្ថាន អ.ប.វ.

### ២.១. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ

#### ២.១.១. ការរៀបចំថ្នាក់រៀន

- ត្រូវរៀបចំតុកៅអីអង្គុយសម្រាប់សិក្ខាកាម សិស្ស និស្សិត នៅក្នុងបន្ទប់រៀន ដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងហោច១,៥ម៉ែត្រ និងមានចំនួនយ៉ាងច្រើន ២០នាក់ ក្នុងមួយថ្នាក់។ ករណីថ្នាក់រៀនដែលមានទំហំធំ គ្រឹះស្ថានអាចរៀបចំតុកៅអីអង្គុយសម្រាប់សិក្ខាកាម សិស្ស និស្សិត លើសពីចំនួន ២០នាក់ ដោយអនុវត្តតាមគម្លាតសុវត្ថិភាព និងវិធានការសុខាភិបាល
- ត្រូវសម្អាត និងអនុវត្តវិធានរម្ងាប់មេរោគ នៅបន្ទប់រៀន និងសម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗរៀងរាល់ថ្ងៃ
- ត្រូវបើកទ្វារ បង្អួច ឬវាំងននឱ្យបានធំទូលាយ ដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់ក្នុងម៉ោងសិក្សា ឬអនុវត្តន៍
- ត្រូវរក្សាសីតុណ្ហភាពក្នុងបន្ទប់រៀនមិនទាបជាង ២៤អង្សាសេ
- ត្រូវរៀបចំបិទផ្សាយរូបភាពអំពីវិធានការ "៣ការពារ" និង"៣កុំ" និងវិធានការសំខាន់ៗរបស់ក្រសួងសុខាភិបាល។

#### ២.១.២. ការរៀបចំរោងជាង បន្ទប់ពិសោធន៍ និងមជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព

- រៀបចំមានគម្លាតពីគ្នាយ៉ាងតិច ១,៥ម៉ែត្រ ឬរៀបចំតុ និងកៅអីអង្គុយ ៤នាក់ ក្នុងទំហំ ១០ម៉ែត្រការ៉េ តាមការណែនាំរបស់អង្គការសុខភាពពិភពលោក
- សម្អាតឧបករណ៍ សម្ភារ បរិក្ខារ ទាំងអស់ឱ្យបានស្អាត ដោយប្រើប្រាស់អាល់កុលបាញ់ទាំងមុនពេល និងក្រោយពេលអនុវត្ត
- ត្រូវពាក់ស្រោមដៃ ឯកសណ្ឋាន និងម៉ាស់ រាល់ពេលអនុវត្ត
- ត្រូវបើកបង្អួចឱ្យមានខ្យល់ និងពន្លឺថ្ងៃចេញចូលបានល្អ

- ត្រូវរៀបចំបិទផ្សាយរូបភាពអំពីវិធានការ "៣ការពារ" និង"៣កុំ" និងវិធានការសំខាន់ៗរបស់ក្រសួងសុខាភិបាល
- រៀបចំឱ្យមានអាល់កុល ឬជែល ឬសាប៊ូ និងទឹកស្អាតសម្រាប់លាងដៃ និងការពាក់ម៉ាស់ មុនពេលអនុញ្ញាតឱ្យចូលក្នុងរោងជាង បន្ទប់ពិសោធន៍ និងមជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព។

**២.១.៣. ការរៀបចំអន្តេវាសិកដ្ឋាន**

- ត្រូវសម្អាត និងអនុវត្តវិធានរម្ងាប់មេរោគ នៅតាមបន្ទប់ស្នាក់នៅ និងឧបករណ៍បរិក្ខារ ប្រើប្រាស់ផ្សេងៗ រៀងរាល់១សប្តាហ៍ម្តង
- ត្រូវបើកទ្វារ បង្អួច ឬវាំងននឱ្យបានធំទូលាយ ដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់
- សិក្ខាកាម សិស្ស និស្សិត ក្នុងអំឡុងពេលស្នាក់នៅ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវបទបញ្ជាផ្ទៃក្នុងអន្តេវាសិកដ្ឋាន
- ត្រូវរៀបចំបិទផ្សាយរូបភាពអំពីវិធានការ "៣ការពារ" និង"៣កុំ" និងវិធានការសំខាន់ៗរបស់ក្រសួងសុខាភិបាល។

**២.២. ការរៀបចំបរិស្ថាន សន្តិសុខ និងសណ្តាប់ធ្នាប់**

- ត្រូវរៀបចំគ្រប់គ្រងការទុកដាក់សំរាម ការធ្វើអនាម័យបោសសម្អាតបន្ទប់រៀន អគារ និងបរិវេណគ្រឹះស្ថាន អ.ប.វ. ឱ្យបានត្រឹមត្រូវរៀងរាល់ថ្ងៃ
- ត្រូវពាក់ម៉ាស់ ពាក់ស្រោមដៃ និងស្បែកជើងឱ្យបានត្រឹមត្រូវមុនពេល និងក្នុងពេលសម្អាត ចំពោះអ្នកទទួលខុសត្រូវការសម្អាត
- ត្រូវចៀសវាងការប្រមូលផ្តុំគ្រប់រូបភាព ទាំងអំឡុងពេលម៉ោងសិក្សា អនុវត្ត ឬក្រៅម៉ោងសិក្សា
- ត្រូវរក្សាគម្លាតសុវត្ថិភាពយ៉ាងហោច ១,៥ម៉ែត្រឡើងទៅ នៅក្នុងការប្រាស្រ័យទាក់ទងនានា ក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ.
- ត្រូវផ្អាកកន្លែងកំសាន្ត ឬទីលានកីឡា ដែលមានលក្ខណៈប្រមូលផ្តុំក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. ជាបណ្តោះអាសន្ន
- ត្រូវហាមឃាត់ការរៀបចំព្រឹត្តិការណ៍សហគមន៍ ឬការជួបជុំណាមួយនៅក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. ដើម្បីចៀសវាងហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩
- ត្រូវរៀបចំវិធានការកុំឱ្យមានការកកស្ទះពេលចេញ-ចូលនៅតាមគ្រឹះស្ថាន អ.ប.វ. ដោយកំណត់កាលវិភាគច្បាស់លាស់អំពីការមកដល់ និងពេលចេញរបស់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ដើម្បីកុំឱ្យចូល និងចេញក្នុងពេលតែមួយ ទាំងក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. និងពេលចូលក្នុងថ្នាក់រៀន បន្ទប់ពិសោធន៍ រោងជាង និងមជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព
- ត្រូវបើកច្រកទ្វារចេញ-ចូលក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. ទាំងអស់ ដើម្បីកាត់បន្ថយការប្រមូលផ្តុំមនុស្សច្រើនកកកុញតាមច្រកចេញ-ចូល ដោយតម្រូវឱ្យឈរតម្រង់ជួរឃ្លាតពីគ្នាចាប់ពី ១,៥ម៉ែត្រឡើងទៅ
- ត្រូវបិទទ្វាររបងគ្រឹះស្ថាន អ.ប.វ. ព្រមទាំងចាត់តាំងអ្នកយាមកាមឱ្យបានហ្មត់ចត់ អំឡុងពេលម៉ោងសិក្សា ដោយមិនអនុញ្ញាតឱ្យអ្នកគ្មានភារកិច្ចចេញ-ចូលឡើយ។

## ២.៣. ការលើកកម្ពស់សុខភាព

- បង្កើតទម្លាប់រស់នៅធម្មតាតាមគន្លងប្រក្រតីភាពថ្មី ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការរបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាល
- ត្រូវប្រើប្រាស់ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំពោះបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ដែលមានរោគសញ្ញាសង្ស័យ មុនបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ
- ត្រូវពិនិត្យលទ្ធភាពរៀបចំបន្ទប់សុខភាពនៅតាមគ្រឹះស្ថាន អ.ប.វ. នីមួយៗ
- ត្រូវណែនាំឱ្យបុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ. បំពេញព័ត៌មានសុខភាព ដើម្បីពិនិត្យតាមដាន និងរក្សាទុកឯកសារ
- ត្រូវរៀបចំម៉ាស៊ីនបាញ់អាល់កុលលាងសម្អាតដៃឱ្យបានច្រើនកន្លែងនៅជិតបង្គន់អនាម័យ បន្ទប់រៀន រោងជាង បន្ទប់ពិសោធន៍ មជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព អាហារដ្ឋាន និងអន្តេវាសិកដ្ឋាន
- ត្រូវថែទាំ និងសម្អាតបង្គន់អនាម័យឱ្យស្អាតជាប្រចាំ ដោយមានទឹក និងសាប៊ូ
- ត្រូវចាត់វិធានការពាក់ម៉ាស់ និងវាស់កម្តៅ ដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ. ជាប្រចាំ
- ករណីរកឃើញមានរោគសញ្ញាសង្ស័យដូចជា ក្អក ឈឺក ពិបាកដកដង្ហើម ឈឺក្បាល ហៀរសំបោរ កណ្តាស់ ផ្តាសសាយ រាគរូស ចុកខ្លួនប្រាណ និងមានកម្តៅចាប់ពី ៣៧,៥ អង្សាសេឡើងទៅ ត្រូវណែនាំឱ្យទៅធ្វើតេស្តរកកូវីដ-១៩ និងព្យាបាលនៅទីតាំងណាមួយស្របតាមនីតិវិធីជាធរមាន
- ត្រូវពិនិត្យឱ្យមានទឹកស្អាតគ្រប់គ្រាន់សម្រាប់ប្រើប្រាស់នៅតាមគ្រឹះស្ថាន អ.ប.វ. ជូនដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត និងលើកទឹកចិត្តឱ្យយកទឹកស្អាតពីផ្ទះសម្រាប់ទុកទទួលទានផ្ទាល់ខ្លួន
- ត្រូវពិនិត្យលទ្ធភាពបំពាក់ឧបករណ៍ បរិក្ខារសម្រាប់ផលិតទឹកស្អាត ឬចម្រោះទឹកដើម្បីទទួលទាន។

## ២.៤. ការផ្តល់សេវាកម្មនៅអាហារដ្ឋាន

- ត្រូវរៀបចំឱ្យមានកន្លែងលាងសម្អាតដៃ
- ត្រូវរៀបចំឱ្យមានម៉ាស៊ីនវាស់កម្តៅ និង QR CODE មុនពេលចូលទទួលទានអាហារ
- ត្រូវរៀបចំសណ្តាប់ធ្នាប់កន្លែងទទួលទានចំណីអាហារប្រកបដោយអនាម័យ និងត្រូវកំណត់ឱ្យអ្នកទទួលទានទាំងអស់ស្ថិតនៅឃ្លាតពីគ្នាចាប់ពី១,៥ ម៉ែត្រឡើងទៅ ដោយមិនត្រូវអនុញ្ញាតឱ្យសិក្ខាកាម សិស្ស និស្សិត ហូបអាហាររួមគ្នា ឬចែករំលែកចំណីអាហារគ្នា ឬអង្គុយហូបចំណីអាហារកកកុញក្បែរគ្នានោះឡើយ
- ត្រូវបាញ់ទឹកថ្នាំ ឬអាល់កុលសម្លាប់មេរោគ នៅតាមតុអាហារមុន និងក្រោយពេលទទួលទាន។

## ២.៨. ការអប់រំសុខភាព និងបណ្តុះបណ្តាលអំពីវិធាននៃការបង្ការជំងឺកូវីដ-១៩

- ត្រូវរៀបចំបិទផ្សាយរូបភាព និងខិតបណ្ណអប់រំសុខភាពនានា ជាពិសេសរបៀបលាងសម្អាតដៃ វិធីការពារបង្ការជំងឺកូវីដ-១៩ នៅក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. ឱ្យបានច្រើនកន្លែងដែលអាចមើលឃើញ
- ត្រូវរៀបចំ និងពង្រឹងការអប់រំផ្សព្វផ្សាយខ្លឹមសារសុវត្ថិភាពសុខភាពសាធារណៈសំខាន់ៗពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ ឬជំងឺឆ្លងស្រួចស្រាវនានាដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ.
- ត្រូវរៀបចំណែនាំដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិតនៅតាមគ្រឹះស្ថាន អ.ប.វ. ស្តីពីសារសំខាន់នៃការរក្សាគម្លាតសុវត្ថិភាព ការបង្ការជំងឺកូវីដ-១៩ និងការសម្លាប់មេរោគនៅតាមគ្រឹះស្ថាន អ.ប.វ.
- ត្រូវប្រើប្រាស់ និងជឿជាក់លើប្រព័ន្ធព័ត៌មានដែលមានប្រភពច្បាស់លាស់ និងផ្លូវការ ស្តីពីស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដូចជាក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ត្រូវណែនាំបុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ. ឱ្យគ្រប់គ្រងអារម្មណ៍ខ្លួនឯងឱ្យបានល្អ ដោយមិនត្រូវស្ថិតក្រោមទស្សនៈ "ការភ័យខ្លាច និងការរើសអើង" ដែលអាចធ្វើឱ្យស្ថានភាពកាន់តែធ្ងន់ធ្ងរ
- ត្រូវណែនាំដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិតក្នុងគ្រឹះស្ថាន អ.ប.វ. ឬអ្នកដទៃទៀតដែលចូលទំនាក់ទំនងជាមួយគ្រឹះស្ថាន អ.ប.វ. ៖
    - មិនត្រូវខាកស្តោះ ឬញើសសំបោរ នៅក្នុងបន្ទប់រៀន បន្ទប់ប្រជុំ បណ្ណាល័យ បន្ទប់ពិសោធន៍ រោងជាង មជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព ឬក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. ជាដាច់ខាត
    - ធ្វើការខ្ទប់មាត់ និងច្រមុះនៅពេលក្អក ឬកណ្តាស់ដោយប្រើគន្លាក់កែងដៃ ឬក្រដាសអនាម័យ រួចបោះចោលក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ
    - មិនត្រូវប៉ះពាល់គ្នាដោយផ្ទាល់ដូចជា ការចាប់ដៃ ឬប្រើប្រាស់របស់របររួមគ្នា និងត្រូវលើកកម្ពស់ការគោរពគ្នា ដោយការសំពះតាមទំនៀមទម្លាប់ខ្មែរ
- ត្រូវណែនាំអ្នកបើកបររថយន្តដឹកសិក្ខាកាម សិស្ស និស្សិត ឱ្យពាក់ម៉ាសការពារជាប់ជាប្រចាំនៅពេលបើកបរ បើកបង្អួច ឬវាំងននឱ្យខ្យល់ចេញ-ចូលបានល្អ និងអនុវត្តរក្សាគម្លាតកន្លែងអង្គុយដោយទុកចន្លោះ១កៅអី
- ត្រូវពិនិត្យកម្តៅសិក្ខាកាម សិស្ស និស្សិត មុនអនុញ្ញាតឱ្យឡើងជិះរថយន្ត។ ប្រសិនបើឃើញថាមានកម្តៅលើសពី ៣៧,៥អង្សាសេឡើងទៅ មិនត្រូវអនុញ្ញាតឱ្យឡើងជិះរថយន្តនោះទេ។ មុនពេលឡើងជិះរថយន្ត ត្រូវកំណត់ឱ្យសិក្ខាកាម សិស្ស និស្សិត និងអ្នកបើកបរលាងសម្អាតដៃនឹងទឹកអាល់កុល ឬទឹកដែលលាងដៃ រយៈពេល ២០វិនាទីជាមុនសិន។

### ៣. ការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធ

#### ៣.១. គ្រឹះស្ថាន អ.ប.វ.

- ត្រូវបង្កើតក្រុមការងារបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩
- ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំពោះបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ដែលមានរោគសញ្ញាសង្ស័យ មុនបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ
- ផ្តល់នូវបញ្ជីឈ្មោះ និងព័ត៌មានចាំបាច់របស់សិក្ខាកាម សិស្ស និស្សិត ដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយអ្នកមានវិជ្ជមានកូវីដ-១៩
- ផ្តល់ទីតាំង និងកិច្ចសហការក្នុងការយកសំណាក
- ចាត់តាំងបុគ្គលិកផ្នែករដ្ឋបាលរបស់គ្រឹះស្ថាន អ.ប.វ. ចំនួន២រូប ដើម្បីទំនាក់ទំនងស្រង់ព័ត៌មានអំពីស្ថានភាពសុខភាពបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស សិក្ខាកាម សិស្ស និស្សិត ដែលត្រូវធ្វើចត្តាឡីស័កជូនអាជ្ញាធរដែនដី
- សហការជាមួយអាជ្ញាធរដែនដី ក្នុងករណីរកឃើញបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស សិក្ខាកាម សិស្ស និស្សិត មានការឆ្លងជំងឺកូវីដ-១៩ ដើម្បីនាំទៅព្យាបាល
- ត្រូវផ្តល់បញ្ជីឈ្មោះបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស សិក្ខាកាម សិស្ស និស្សិត ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២
- ករណីគ្រឹះស្ថាន អ.ប.វ. ត្រូវបានផ្អាកដំណើរការដោយមានការឆ្លងជំងឺកូវីដ-១៩ ត្រូវដាក់ពាក្យស្នើសុំបើកដំណើរការគ្រឹះស្ថានឡើងវិញទៅគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ
- គ្រឹះស្ថាន អ.ប.វ. ត្រូវរៀបចំ និងផ្ញើរបាយការណ៍ប្រចាំសប្តាហ៍ ឬពេលវេលាកំណត់ណាមួយស្តីពីវឌ្ឍនភាពអំពីស្ថានភាពនៃជំងឺកូវីដ-១៩ រួចបញ្ជូនមកគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ តាមរយៈតេឡេក្រាមឈ្មោះ TVET Re-Opening Board (https://t.me/joinchat/0HBAKmLatp9jOGY1)។

#### ៣.២. សិក្ខាកាម សិស្ស និស្សិត

- ត្រូវបង្ហាញកាតចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ដល់គ្រឹះស្ថាន អ.ប.វ. ហើយក្នុងករណីពុំទាន់បានចាក់វ៉ាក់សាំង ត្រូវទំនាក់ទំនងជាមួយអាជ្ញាធរដែនដី
- ត្រូវចូលរួមធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ តាមការកំណត់របស់គ្រឹះស្ថាន អ.ប.វ. និងអាជ្ញាធរដែនដី ក្នុងករណីមានរោគសញ្ញាសង្ស័យ
- ករណីវិជ្ជមានកូវីដ-១៩ ត្រូវទៅសម្រាកព្យាបាលតាមការណែនាំរបស់អាជ្ញាធរដែនដី និងមន្ត្រីសុខាភិបាល

- ករណីមានការពាក់ព័ន្ធ ឬប៉ះពាល់ផ្ទាល់ជាមួយអ្នកវិជ្ជមានកូវីដ-១៩ ត្រូវធ្វើចត្តាឡីស័កតាមការកំណត់ និងត្រូវរាយការណ៍ជូនផ្នែករដ្ឋបាលនៃគ្រឹះស្ថាន អ.ប.វ.តាមនីតិវិធីជាធរមាន
- ត្រូវអនុវត្តឱ្យបានត្រឹមត្រូវនូវបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន អ.ប.វ.
- មិនត្រូវដើរឆ្លងពីអគារសិក្សា ឬរោងជាង ឬបន្ទប់ពិសោធន៍មួយ ទៅអគារសិក្សា ឬរោងជាង ឬបន្ទប់ពិសោធន៍មួយផ្សេងទៀតដោយគ្មានការអនុញ្ញាត
- អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ "៣ការពារ" និង"៣កុំ" និងវិធានការសុខាភិបាលនានា។

### ៣.៣. អង្គភាពពាក់ព័ន្ធនានា និងអាជ្ញាធរដែនដី

គ្រឹះស្ថាន អ.ប.វ. ត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធនានា និងអាជ្ញាធរដែនដីដូចខាងក្រោម៖

- សហការជាមួយក្រសួង ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចូលរួមអនុវត្តការការគ្រប់គ្រងការបង្ការ ការទប់ស្កាត់ និងការរីករាលដាលនៃជំងឺកូវីដ-១៩
- សហការជាមួយមន្ទីរសុខាភិបាល ឬមន្ត្រីសុខាភិបាល ដើម្បីអន្តរាគមន៍ជាបន្ទាន់ ក្នុងការយកសំណាកការពិនិត្យព្យាបាលជូនដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិតក្នុងករណីមានការសង្ស័យ ឬមានវិជ្ជមានជំងឺកូវីដ-១៩
- សហការជាមួយអាជ្ញាធរដែនដីក្នុងការទទួលបានព័ត៌មានពីហានិភ័យដែលអាចកើតមានឡើងពីការចេញចូលនៃប្រជាជនចំណាកស្រុកនៅតាមមូលដ្ឋាន ឬព័ត៌មានពីការគ្រប់គ្រងអ្នកចំណូលថ្មី ឬព័ត៌មានពីការជួបជុំនានាដែលអាចបង្កហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩
- សហការជាមួយអាជ្ញាធរដែនដី អាណាព្យាបាល វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានាដើម្បីស្វែងរកធនធានសម្ភារ និងធនធានថវិកា ក្នុងការគាំទ្រដល់ការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ។

## ៤. ការវាយតម្លៃហានិភ័យ

- ករណីគ្រឹះស្ថាន អ.ប.វ. ស្ថិតនៅតំបន់ក្រហម លឿងទុំ ឬតំបន់បិទខ្ទប់ មិនត្រូវបានអនុញ្ញាតឱ្យបើកដំណើរការឡើយ
- ករណីរកឃើញមានការឆ្លងជំងឺកូវីដ-១៩ ចាប់ពី ១០ភាគរយឡើងទៅ ត្រូវបានចាត់ទុកថាជាកម្រិតហានិភ័យខ្ពស់ ហើយត្រូវផ្អាកដំណើរការជាបណ្តោះអាសន្ន និងរាយការណ៍ជូនមកគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ និងអាជ្ញាធរដែនដីជាបន្ទាន់
- ករណីរកឃើញមានការឆ្លងជំងឺកូវីដ-១៩ ក្រោម ១០ភាគរយ ត្រូវបានចាត់ទុកថាជាកម្រិតហានិភ័យទាប ហើយត្រូវផ្អាកដំណើរការជាបណ្តោះអាសន្ននៅតាមផ្នែកនៃអគារសិក្សា រោងជាង បន្ទប់ពិសោធន៍ ដែលមានករណីឆ្លង និងរាយការណ៍មកគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ និងអាជ្ញាធរដែនដីជាបន្ទាន់
- ត្រូវតាមដានជាប្រចាំរាល់ការវិវត្តន៍ថ្មីៗនៃជំងឺកូវីដ-១៩ និងប្រភេទបំលែងថ្មី ដែលប្រកាសផ្សព្វផ្សាយជាផ្លូវការដោយក្រសួងសុខាភិបាល និងអាជ្ញាធរដែនដី។

## ៥. ការរាយការណ៍អំពីករណីផ្សេងៗ

- ត្រូវជូនដំណឹងដល់គណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ អាជ្ញាធរដែនដី និងមន្ទីរសុខាភិបាលជាបន្ទាន់ ឬតាមរយៈលេខទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ក្នុងករណីមានសង្ស័យមានជំងឺកូវីដ-១៩ ក្នុងចំណោម បុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស សិក្ខាកាម សិស្ស និស្សិត
- ត្រូវផ្តល់ឈ្មោះជនបង្គោលចំនួន ២រូប ជូនទៅគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ មន្ទីរសុខាភិបាល និងអាជ្ញាធរដែនដី ដើម្បីងាយស្រួលទំនាក់ទំនងក្នុងការចូលរួមអង្កេតស្រាវជ្រាវ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ស្របតាមវិធានការនានារបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាល
- ក្នុងករណីគ្រឹះស្ថាន អ.ប.វ. ណាមួយ ពុំបានអនុវត្តតាមការណែនាំរបស់គណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ និងអាជ្ញាធរដែនដី ហើយមានការធ្វេសប្រហែស ដែលបណ្តាលឱ្យមានការផ្ទុះឆ្លងរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. ជាយថាហេតុ គណៈគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ. នោះ នឹងត្រូវប្រឈមមុខនឹងវិធានការរដ្ឋបាលនានាតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន
- ត្រូវរៀបចំ និងផ្ញើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពនៃជំងឺកូវីដ-១៩ នៅក្នុងគ្រឹះស្ថាន អ.ប.វ. រួចបញ្ជូនមកគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ និងអាជ្ញាធរដែនដីឱ្យបានទៀងទាត់។

## ឧបសម្ព័ន្ធទី១

## លក្ខណៈវិនិច្ឆ័យនៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ.

គណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ អនុញ្ញាតឱ្យគ្រឹះស្ថាន អ.ប.វ. បើកដំណើរការឡើងវិញ ដោយអនុវត្តលក្ខណៈវិនិច្ឆ័យចាំបាច់ ដូចខាងក្រោម៖

| លរ | បរិយាយ | មាន ឬមិនមាន | ផ្សេងៗ |
|---|---|---|---|
| ១ | លិខិតស្នើសុំបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញមកគណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ | | |
| ២ | ក្រុមការងារបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ប្រចាំគ្រឹះស្ថាន អ.ប.វ. | | |
| ៣ | បុគ្គលិកទទួលបន្ទុកត្រួតពិនិត្យការពាក់ម៉ាស វាស់កំដៅ បាញ់ទឹកអាល់កុល-ជែលអាល់កុល | | |
| ៤ | កន្លែងលាងសម្អាតដៃនៅតាមច្រកចេញ-ចូល គ្រឹះស្ថាន អ.ប.វ. ថ្នាក់រៀន រោងជាង បន្ទប់ពិសោធន៍ អន្តេវាសិកដ្ឋាន អាហារដ្ឋាន និងបន្ទប់ទឹក | | |
| ៥ | កន្លែងបាញ់ទឹកអាល់កុល-ជែលអាល់កុល នៅច្រកចេញ-ចូល គ្រឹះស្ថាន អ.ប.វ. ថ្នាក់រៀន រោងជាង បន្ទប់ពិសោធន៍ អន្តេវាសិកដ្ឋាន អាហារដ្ឋាន និងបន្ទប់ទឹក | | |
| ៦ | បិទផ្ទាំងរូបភាព និងគំនូសសញ្ញានានាអំពីវិធានការការពារជំងឺកូវីដ-១៩ ក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. | | |
| ៧ | ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (Covid-19 Rapid Antigen Test) ដែលបានចុះបញ្ជិកា ឬទទួលស្គាល់ពីក្រសួងសុខាភិបាល | | |
| ៨ | ស្ថិតិបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស សិក្ខាកាម សិស្ស និស្សិត កំពុងបម្រើការងារ ស្នាក់នៅ និងសិក្សា | | |
| ៩ | ស្ថិតិបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស សិក្ខាកាម សិស្ស និស្សិត បានទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ | | |
| ១០ | របាយការណ៍ស្វ័យវាយតម្លៃ គោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ | | |

## ឧបសម្ព័ន្ធទី២

## លក្ខណវិនិច្ឆ័យនៃការផ្អាកដំណើរការគ្រឹះស្ថាន អ.ប.វ.

គ្រឹះស្ថាន អ.ប.វ. អាចត្រូវបានផ្អាកដំណើរការសកម្មភាពបណ្តុះបណ្តាលក្នុងការបង្ការជំងឺកូវីដ-១៩ ក្នុងរយៈពេលណាមួយ អាស្រ័យលើការពិនិត្យវាយតម្លៃរបស់គណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ ដោយផ្អែកលើលក្ខណវិនិច្ឆ័យចាំបាច់ដូចខាងក្រោម៖

| ល.រ | បរិយាយ | មាន ឬមិនមាន | ផ្សេងៗ |
|---|---|---|---|
| ១ | មានការឆ្លងជំងឺកូវីដ១៩ ចំនួនចាប់ពី ១០ភាគរយឡើង | | |
| ២ | ករណីគ្រឹះស្ថាន អ.ប.វ. ស្ថិតនៅតំបន់ក្រហម លឿងទុំ ឬតំបន់បិទខ្ទប់ | | |
| ៣ | មានសភាពធ្ងន់ធ្ងរ និងស្មុគស្មាញនៃការឆ្លងជំងឺកូវីដ-១៩ ក្នុងគ្រឹះស្ថាន អ.ប.វ. ដោយមិនអាចគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលបន្តជាពិសេស មិនអាចដឹងអំពីប្រភពនៃការឆ្លង និងមិនអាចញែកអ្នកដែលពាក់ព័ន្ធផ្ទាល់ និងប្រយោល | | |
| ៤ | មានសិក្ខាកាម សិស្ស និស្សិត មានកន្លែងស្នាក់នៅស្ថិតក្នុងតំបន់ដែលកំពុងផ្ទុះវិជ្ជមានកូវីដ-១៩ ឬមានហានិភ័យខ្ពស់ក្នុងការឆ្លងរាលដាលជំងឺកូវីដ-១៩ | | |
| ៥ | មានការដឹកជញ្ជូនសិក្ខាកាម សិស្ស និស្សិត ចេញពីកន្លែង ដែលកំពុងផ្ទុះវិជ្ជមានកូវីដ-១៩ ឬដែលត្រូវបានវាយតម្លៃថាមានហានិភ័យខ្ពស់ក្នុងការឆ្លងរាលដាលជំងឺកូវីដ-១៩ | | |
| ៦ | មិនអាចរៀបចំឱ្យមានគម្លាតសុវត្ថិភាព និងអនាម័យល្អនៅតាមទីតាំងដែលប្រើប្រាស់រួម ដូចជា បង្គន់ ជណ្តើរ ច្រកចេញ-ចូល។ល។ | | |
| ៧ | មិនអាចរៀបចំឱ្យមានគម្លាតសុវត្ថិភាពចំពោះសិក្ខាកាម សិស្ស និស្សិតនៅបន្ទប់សិក្សា រោងជាង បន្ទប់ពិសោធន៍ | | |
| ៨ | មានបន្ទប់តូចចង្អៀត ឬបិទជិត គ្មានខ្យល់ចេញ-ចូលគ្រប់គ្រាន់ ដែលអាចបង្កហានិភ័យខ្ពស់ក្នុងការឆ្លងរីករាលដាលជំងឺកូវីដ-១៩ | | |
| ៩ | មិនមានការចាត់តាំងមន្ត្រីទទួលខុសត្រូវលើការបាញ់អាល់កុល, មិនមានកន្លែងវាស់កម្តៅនៅច្រកចេញ-ចូល, កន្លែងលាងសម្អាតដៃ, មិនមានសាប៊ូ ឬអាល់កុលគ្រប់គ្រាន់នៅតាមកន្លែងលាងសម្អាតដៃ, មិនមានការបាញ់ថ្នាំសម្លាប់មេរោគជាប្រចាំសប្តាហ៍នៅក្នុងបន្ទប់សិក្សា រោងជាងអន្តេវាសិកដ្ឋាន មជ្ឈមណ្ឌលតេស្តសមត្ថភាព ។ល។ | | |
| ១០ | មិនផ្តល់កិច្ចសហការពេញលេញដល់គណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ ឬអាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យវាយតម្លៃ ដើម្បីកំណត់ចំនួនអ្នកប៉ះពាល់ផ្ទាល់និងប្រយោលជាមួយនឹងអ្នកមានវិជ្ជមានកូវីដ-១៩ ព្រមទាំងកម្រិតហានិភ័យនៃការឆ្លងរាលដាលបន្ត។ | | |
| ១១ | របាយការណ៍វាយតម្លៃហានិភ័យរបស់គណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ | | |

## ឧបសម្ព័ន្ធទី៣
## សមាសភាព និងតួនាទីភារកិច្ចរបស់
## គណៈកម្មការគ្រប់គ្រង និងវាយតម្លៃការបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ

សមាសភាព៖

| | | |
|---|---|---|
| ១. | ថ្នាក់ដឹកនាំទទួលបន្ទុកនៃវិស័យ អ.ប.វ. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២. | ថ្នាក់ដឹកនាំទទួលបន្ទុកនៃវិស័យ អ.ប.វ. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣. | តំណាងអគ្គនាយកដ្ឋាន អ.ប.វ. | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. | តំណាងអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៥. | តំណាងនាយកដ្ឋានពេទ្យការងារ | សមាជិក |
| ៦. | តំណាងគ្រប់គ្រឹះស្ថាន អ.ប.វ. | សមាជិក |
| ៧. | នាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា | ជាលេខាធិការ |

តួនាទីភារកិច្ច៖

- ត្រួតពិនិត្យ និងវាយតម្លៃការលើសំណុំបែបបទស្នើសុំបើកដំណើរការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ឡើងវិញ
- រៀបចំលិខិតបទដ្ឋានគតិយុទ្ធផ្សេងៗក្នុងការបង្ការ ការទប់ស្កាត់នៃជំងឺកូវីដ-១៩
- ជំរុញគ្រឹះស្ថាន អ.ប.វ. ក្នុងការអនុវត្តវិធានការ និងសេចក្តីណែនាំនានាស្តីពីការលើកកម្ពស់សុខភាព ការបង្ការជំងឺ ឬការបង្ការគ្រោះថ្នាក់នានាដែលក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងរាជរដ្ឋាភិបាល បានដាក់ចេញនាពេលកន្លងមក
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាសម្រាប់ដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ ក្នុងបរិបទកូវីដ-១៩ តាមគ្រឹះស្ថាន អ.ប.វ.
- ត្រួតពិនិត្យ និងវាយតម្លៃក្នុងការផ្អាកដំណើរការគ្រឹះស្ថាន អ.ប.វ.
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃរៀងរាល់សប្តាហ៍លើស្ថានភាពជំងឺកូវីដ-១៩ ជាពិសេសប្រភេទបំប្លែងថ្មី
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធ ឬដៃគូអភិវឌ្ឍនានា ក្នុងការការបង្ការ ការទប់ស្កាត់នៃរីករាលដាលជំងឺកូវីដ-១៩ ស្វែងរកសម្ភារ ថវិកា ពីប្រភពផ្សេងៗទៀត ដើម្បីជួយដល់គ្រឹះស្ថាន អ.ប.វ.
- រៀបចំយន្តការចាំបាច់នានាផ្សេងទៀតតាមការណែនាំរបស់រាជរដ្ឋាភិបាល
- ត្រូវអនុវត្តភារកិច្ចផ្សេងៗតាមការចាត់តាំងរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ឧបសម្ព័ន្ធទី៤**

# កិច្ចសន្យា
# ស្តីពី
# ការបើកដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ឡើងវិញក្នុងបរិបទកូវីដ-១៩
# រវាង
# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
# ជាមួយនឹង

**គ្រឹះស្ថាន៖**..................................................................................................

**យោង៖** - លិខិតលេខ....................ចុះថ្ងៃទី.........ខែ..................ឆ្នាំ២០២១ របស់...........................................................

- របាយការណ៍ស្វ័យវាយតម្លៃនៃ...................................................................................................។

កិច្ចសន្យានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងកំណត់អំពីការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងនៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការធានានូវការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ឡើងវិញក្នុងបរិបទកូវីដ-១៩។

កិច្ចសន្យានេះត្រូវបានធ្វើឡើងរវាងតំណាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហៅថា ភាគី "**ក្រសួង**" ដែលមានអាស័យដ្ឋាននៅអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមួយនឹងតំណាងវិទ្យាស្ថាន.................................................................................... ដែលមានអាស័យដ្ឋាននៅ..................................................................................................................
ហៅថាភាគី "**គ្រឹះស្ថាន អ.ប.វ.**" ដោយបានព្រមព្រៀងគ្នាដូចខាងក្រោម៖

**ប្រការ១ .–** ភាគី "ក្រសួង" បានយល់ព្រមអនុញ្ញាតឱ្យ ភាគី "គ្រឹះស្ថាន អ.ប.វ." បើកដំណើរការវិទ្យាស្ថាន..............................................ឡើងវិញ ចាប់ពីថ្ងៃ..............................................តទៅ។

**ប្រការ២ .–** ភាគី "គ្រឹះស្ថាន អ.ប.វ." បានយល់ព្រមផ្សព្វផ្សាយគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ឡើងវិញក្នុងបរិបទកូវីដ-១៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់បុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស សិក្ខាកាម សិស្ស និស្សិត របស់ខ្លួនឱ្យបានទូលំទូលាយ។

**ប្រការ៣ .–** ភាគី "គ្រឹះស្ថាន អ.ប.វ." បានយល់ព្រមអនុវត្តតាមខ្លឹមសារនៃគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) ឡើងវិញក្នុងបរិបទកូវីដ-១៩ ដោយការយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់។

ប្រការ៤ ._ ភាគី "គ្រឹះស្ថាន អ.ប.វ." បានយល់ព្រមអនុញ្ញាតជូនប្រតិភូ ឬអ្នកតំណាងរបស់ ភាគី "ក្រសួង" ចុះត្រួតពិនិត្យដោយមាន ឬដោយពុំមានការជម្រាបជូនជាមុន លើការអនុវត្តនៃកិច្ចសន្យានេះ។ ក្នុងករណីនេះ ភាគី "គ្រឹះស្ថាន អ.ប.វ." ត្រូវស្នើសុំឱ្យប្រតិភូ ឬអ្នកតំណាងរបស់ ភាគី "ក្រសួង" បង្ហាញលិខិតបញ្ជាបេសកកម្ម ដែលចេញដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយត្រូវផ្តល់កិច្ចសហការឱ្យបានពេញលេញបំផុត។

ប្រការ៥ ._ ភាគី "គ្រឹះស្ថាន អ.ប.វ." បានសុខចិត្តទទួលខុសត្រូវគ្រប់បែបយ៉ាងនៅចំពោះមុខច្បាប់ និងវិធានការចាំបាច់នានា របស់អាជ្ញាធរមានសមត្ថកិច្ចចំពោះគ្រប់ហានិភ័យនឹងអាចកើតឡើងជាយថាហេតុនៃការផ្ទុះឡើង និងការរីករាលដាលនៃជំងឺកូវីដ-១៩ បន្ទាប់ពីការសម្រេចចិត្តបើកដំណើរការឡើងវិញគ្រឹះស្ថាន អ.ប.វ.។

ប្រការ៦ ._ កិច្ចសន្យានេះ មានសុពលភាព ចាប់ពីថ្ងៃចុះហត្ថលេខាទទួលស្គាល់ដោយអគ្គនាយកនៃអគ្គនាយដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលជាតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ប្រការ៧ ._ ភាគី "គ្រឹះស្ថាន អ.ប.វ." យល់ព្រមអនុវត្តខ្លឹមសារនៃកិច្ចសន្យានេះ រហូតដល់ថ្ងៃណាមួយដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសជាផ្លូវការថាពុំមានការគំរាមគំហែង ឬហានិភ័យនៃការផ្ទុះឡើង និងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩តទៅទៀត។

ប្រការ៨ ._ ក្នុងករណីជំងឺកូវីដ-១៩ រាតត្បាតខ្លាំង និងមានការប្រកាសអាសន្នរបស់រាជរដ្ឋាភិបាល ឬក្រសួងសុខាភិបាល ឬអង្គការសុខភាពពិភពលោក កិច្ចសន្យានេះនឹងត្រូវផ្អាកដោយស្វ័យប្រវត្តិ។

ដើម្បីជាសក្ខីភាព ក្នុងការយល់ព្រមទាំងស្រុងលើខ្លឹមសារនៃកិច្ចសន្យានេះ ភាគី "គ្រឹះស្ថាន អ.ប.វ." និងភាគី "ក្រសួង" សូមចុះហត្ថលេខាលើកិច្ចសន្យានេះជាពីរច្បាប់ ដោយតម្កល់មួយច្បាប់ ដោយភាគី "គ្រឹះស្ថាន អ.ប.វ." និងមួយច្បាប់ទៀតសម្រាប់ប្រគល់ជូន ភាគី "ក្រសួង"។

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | តំណាងគ្រឹះស្ថាន អ.ប.វ.

## ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ឈ្មោះគ្រឹះស្ថាន៖...................................................................

## តារាងស្វ័យវាយតម្លៃនៃគ្រឹះស្ថាន អ.ប.វ.

| ល.រ | សូចនាករនៃការអនុវត្ត | (✓) មាន ឬ (X) មិនទាន់មាន |
|---|---|---|
| គោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញក្នុងបរិបទកូវីដ-១៩ | | |
| ១. | ការរៀបចំថ្នាក់រៀន | |
| ១.១. | រៀបចំតុកៅអីអង្គុយសម្រាប់សិក្ខាកាម សិស្ស និស្សិត នៅក្នុងបន្ទប់រៀន ដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងហោច ១,៥ម៉ែត្រ និងមានចំនួនយ៉ាងច្រើន ២០ នាក់ក្នុងមួយថ្នាក់។ ករណីថ្នាក់រៀនដែលមានទំហំធំ, គ្រឹះស្ថានអាចចំតុកៅអីអង្គុយសម្រាប់សិក្ខាកាម សិស្ស និស្សិតលើសពីចំនួន២០នាក់ ដោយអនុវត្តតាមគម្លាតសុវត្ថិភាព និងវិធានការសុខាភិបាល | |
| ១.២. | សម្អាត និងអនុវត្តវិធានរម្ងាប់មេរោគ នៅបន្ទប់រៀន និងសម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗរៀងរាល់ថ្ងៃ | |
| ១.៣. | បើកទ្វារ បង្អួច ឬវាំងននឱ្យបានធំទូលាយ ដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់ក្នុងម៉ោងសិក្សា ឬអនុវត្តន៍ | |
| ១.៤. | រក្សាសីតុណ្ហភាពក្នុងបន្ទប់រៀនមិនទាបជាង ២៤អង្សាសេ | |
| ១.៥. | រៀបចំបិទផ្សាយរូបភាពអំពីវិធានការ ៣ការពារ និង៣កុំ និងវិធានការសំខាន់ៗរបស់ក្រសួងសុខាភិបាល | |
| ២. | ការរៀបចំរោងជាង បន្ទប់ពិសោធន៍ និងមជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព | |
| ២.១. | រៀបចំមានគម្លាតពីគ្នាយ៉ាងតិច ១,៥ម៉ែត្រ ឬរៀបចំតុ និងកៅអីអង្គុយ ៤នាក់ ក្នុងទំហំ ១០ម៉ែត្រការ៉េ តាមការណែនាំរបស់អង្គការសុខភាពពិភពលោក | |
| ២.២. | សម្អាតឧបករណ៍ សម្ភារ បរិក្ខារ ទាំងអស់ឱ្យបានស្អាត ដោយប្រើប្រាស់អាល់កុលបាញ់ទាំងមុនពេល និងក្រោយពេលអនុវត្ត | |
| ២.៣. | មានស្រោមដៃ ឯកសណ្ឋាន និងម៉ាស់ សម្រាប់ប្រើប្រាស់រាល់ពេលអនុវត្ត | |
| ២.៤. | បើកបង្អួចឱ្យមានខ្យល់ និងពន្លឺថ្ងៃចេញចូលបានល្អ | |
| ២.៥. | រៀបចំបិទផ្សាយរូបភាពអំពីវិធានការ ៣ការពារ និង៣កុំ និងវិធានការសំខាន់ៗរបស់ក្រសួងសុខាភិបាល | |
| ២.៦. | រៀបចំឱ្យមានអាល់កុល ឬជែល ឬសាប៊ូ និងទឹកស្អាតសម្រាប់លាងដៃ និងការពាក់ម៉ាស់ មុនពេលអនុញ្ញាតឱ្យចូលក្នុងរោងជាង បន្ទប់ពិសោធន៍ និងមជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព។ | |
| ៣. | ការរៀបចំអន្តេវាសិកដ្ឋាន | |
| ៣.១. | សម្អាត និងអនុវត្តវិធានរម្ងាប់មេរោគ នៅតាមបន្ទប់ស្នាក់នៅ និងឧបករណ៍បរិក្ខារ ប្រើប្រាស់ផ្សេងៗ រៀងរាល់ ១សប្តាហ៍ម្តង | |

| | | |
|---|---|---|
| ៣.២. | បើកទ្វារ បង្អួច ឬវាំងននឱ្យបានធំទូលាយ ដើម្បីឱ្យពន្លឺថ្ងៃ និងខ្យល់អាកាសចេញចូលគ្រប់គ្រាន់ | |
| ៣.៣. | សិក្ខាកាម សិស្ស និស្សិត ក្នុងអំឡុងពេលស្នាក់នៅ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវបទបញ្ជាផ្ទៃក្នុងអន្តេវាសិកដ្ឋាន | |
| ៣.៤. | រៀបចំបិទផ្សាយរូបភាពអំពីវិធានការ ៣ការពារ និង៣កុំ និងវិធានការសំខាន់ៗរបស់ក្រសួងសុខាភិបាល | |
| ៤. | **ការរៀបចំបរិស្ថាន សន្តិសុខនិងសណ្តាប់ធ្នាប់** | |
| ៤.១. | រៀបចំគ្រប់គ្រងការទុកដាក់សំរាម ការធ្វើអនាម័យបោសសម្អាតបន្ទប់រៀន អគារ និងបរិវេណគ្រឹះស្ថាន អ.ប.វ. ឱ្យបានត្រឹមត្រូវរៀងរាល់ថ្ងៃ | |
| ៤.២. | ពាក់ម៉ាស់ ពាក់ស្រោមដៃ និងស្បែកជើងឱ្យបានត្រឹមត្រូវមុនពេលនិងក្នុងពេលសម្អាត ចំពោះអ្នកទទួលខុសត្រូវការសម្អាត | |
| ៤.៣. | ចៀសវាងការប្រមូលផ្តុំគ្រប់រូបភាព ទាំងអំឡុងពេលម៉ោងសិក្សា អនុវត្ត ឬក្រៅម៉ោងសិក្សា | |
| ៤.៤. | រក្សាគម្លាតសុវត្ថិភាពយ៉ាងហោច ១,៥ម៉ែត្រ ឡើងទៅ នៅក្នុងការប្រាស្រ័យទាក់ទងនានាក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. | |
| ៤.៥. | ផ្អាកកន្លែងកំសាន្ត ឬទីលានកីឡា ដែលមានលក្ខណៈប្រមូលផ្តុំក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. ជាបណ្តោះអាសន្ន | |
| ៤.៦. | ហាមឃាត់ការរៀបចំព្រឹត្តិការណ៍សហគមន៍ ឬការជួបជុំណាមួយនៅក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. ដើម្បីចៀសវាងហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ | |
| ៤.៧. | រៀបចំវិធានការកុំឱ្យមានការកកស្ទះពេលចេញ-ចូលនៅតាមគ្រឹះស្ថាន អ.ប.វ. ដោយកំណត់កាលវិភាគច្បាស់លាស់អំពីការមកដល់និងពេលចេញរបស់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ដើម្បីកុំឱ្យចូល និងចេញក្នុងពេលតែមួយ ទាំងក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. និងពេលចូលក្នុងថ្នាក់រៀន បន្ទប់ពិសោធន៍ រោងជាង និងមជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព | |
| ៤.៨. | បើកច្រកទ្វារចេញ-ចូលក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. ទាំងអស់ ដើម្បីកាត់បន្ថយការប្រមូលផ្តុំមនុស្សច្រើនកកកុញតាមច្រកចេញ-ចូល ដោយតម្រូវឱ្យឈរតម្រង់ជួរឃ្លាតពីគ្នាចាប់ពី ១,៥ ម៉ែត្រឡើងទៅ | |
| ៤.៩. | បិទទ្វាររបងគ្រឹះស្ថាន អ.ប.វ. ព្រមទាំងចាត់តាំងអ្នកយាមកាមឱ្យបានហ្មត់ចត់ អំឡុងពេលម៉ោងសិក្សា ដោយមិនអនុញ្ញាតឱ្យអ្នកគ្មានភារកិច្ចចេញ-ចូលឡើយ | |
| ៥. | **ការលើកកម្ពស់សុខភាព** | |
| ៥.១. | បង្កើតទម្លាប់រស់នៅធម្មតាតាមគន្លងប្រក្រតីភាពថ្មី ដោយអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការរបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាល | |
| ៥.២. | ក្រុមការងារបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ | |
| ៥.៣. | ប្រើប្រាស់ឧបករណ៍តេស្តរហ័សរករង់ទីហ្សែនកូវីដ-១៩ ចំពោះបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត ដែលមានអាការៈ រោគសញ្ញាសង្ស័យ មុនបើកដំណើរការគ្រឹះស្ថាន អ.ប.វ. ឡើងវិញ | |
| ៥.៤. | ពិនិត្យលទ្ធភាពរៀបចំបន្ទប់សុខភាពនៅតាមគ្រឹះស្ថាន អ.ប.វ. នីមួយៗ | |

| | | |
|---|---|---|
| ៥.៥. | ណែនាំឱ្យបុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ. បំពេញព័ត៌មានសុខភាព ដើម្បីពិនិត្យតាមដាន និងរក្សាទុកឯកសារ | |
| ៥.៦. | រៀបចំម៉ាស៊ីនបាញ់អាល់កុលលាងសម្អាតដៃឱ្យបានច្រើនកន្លែងនៅជិតបង្គន់អនាម័យ បន្ទប់រៀន រោងជាង បន្ទប់ពិសោធន៍ មជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព អាហារដ្ឋាន និងអន្តេវាសិកដ្ឋាន | |
| ៥.៧. | ថែទាំ និងសម្អាតបង្គន់អនាម័យឱ្យស្អាតជាប្រចាំ ដោយមានទឹក និងសាប៊ូ | |
| ៥.៨. | ចាត់វិធានការពាក់ម៉ាស់ និងវាស់កម្តៅ ដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ. ជាប្រចាំ។ ករណីរកឃើញមានកម្តៅចាប់ពី ៣៧.៥ អង្សាសេ ឡើងទៅ មិនត្រូវអនុញ្ញាតឱ្យចូលក្នុងគ្រឹះស្ថាន អ.ប.វ. ឡើយ ហើយត្រូវណែនាំនិងអនុញ្ញាតឱ្យសម្រាកនៅផ្ទះ ឬទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាព | |
| ៥.៩. | កំណត់មុខសញ្ញាបុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស ឬសិក្ខាកាម សិស្ស និស្សិតដែលត្រូវយកសំណាកនៅពេលបើកដំណើរការឡើងវិញ | |
| ៥.១០. | ពិនិត្យឱ្យមានទឹកស្អាតគ្រប់គ្រាន់សម្រាប់ប្រើប្រាស់នៅតាមគ្រឹះស្ថាន អ.ប.វ. ជូនដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត និងលើកទឹកចិត្តឱ្យយកទឹកស្អាតពីផ្ទះសម្រាប់ទុកទទួលទានផ្ទាល់ខ្លួន | |
| ៥.១១. | ពិនិត្យលទ្ធភាពបំពាក់ឧបករណ៍ បរិក្ខារសម្រាប់ផលិតទឹកស្អាតឬចម្រោះទឹកដើម្បីទទួលទាន | |
| **៦.** | **ការផ្តល់សេវាកម្មនៅអាហារដ្ឋាន** | |
| ៦.១. | កន្លែងលាងសម្អាតដៃ | |
| ៦.២. | ម៉ាស៊ីនវាស់កម្តៅ និង QR CODE មុនពេលចូលទទួលទានអាហារ | |
| ៦.៣. | សណ្តាប់ធ្នាប់កន្លែងទទួលទានចំណីអាហារប្រកបដោយអនាម័យ និងត្រូវកំណត់ឱ្យអ្នកទទួលទានទាំងអស់ស្ថិតនៅឃ្លាតពីគ្នាចាប់ពី ១,៥ ម៉ែត្រឡើងទៅ ដោយមិនត្រូវអនុញ្ញាតឱ្យសិក្ខាកាមសិស្ស និស្សិត ញ៉ាំអាហាររួមគ្នា ឬចែករំលែកចំណីអាហារគ្នា ឬអង្គុយញ៉ាំចំណីអាហារកកកុញក្បែរគ្នានោះឡើយ | |
| ៦.៤. | បាញ់ទឹកថ្នាំ ឬអាល់កុលសម្លាប់មេរោគ នៅតាមតុអាហារមុននិងក្រោយពេលទទួលទាន | |
| **៧.** | **ការអប់រំសុខភាព និងបណ្តុះបណ្តាលអំពីវិធាននៃការបង្ការជំងឺកូវីដ-១៩** | |
| ៧.១. | បិទផ្សាយរូបភាព និងខិតបណ្ណអប់រំសុខភាពនានា ជាពិសេសរបៀបលាងសម្អាតដៃ វិធីការពារបង្ការជំងឺកូវីដ-១៩ នៅក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ. ឱ្យបានច្រើនកន្លែងដែលអាចមើលឃើញនិងយកជាគំរូ | |
| ៧.២. | រៀបចំ និងពង្រឹងការអប់រំផ្សព្វផ្សាយខ្លឹមសារសុវត្ថិភាពសុខភាពសាធារណៈសំខាន់ៗពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ ឬជំងឺឆ្លងស្រួចស្រាវនានាដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេក-ទេស និងសិក្ខាកាម សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ. | |
| ៧.៣. | រៀបចំណែនាំដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិតនៅតាមគ្រឹះស្ថាន អ.ប.វ. ស្តីពីសារសំខាន់នៃការរក្សាគម្លាតសុវត្ថិភាព ការបង្ការជំងឺកូវីដ-១៩ និងការសម្លាប់មេរោគនៅតាមគ្រឹះស្ថាន អ.ប.វ. | |
| ៧.៤. | ប្រើប្រាស់ និងជឿជាក់លើប្រព័ន្ធព័ត៌មានដែលមានប្រភពច្បាស់លាស់ និងផ្លូវការ ស្តីពីស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដូចជាក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក ឬក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | |

| | | |
|---|---|---|
| ៧.៥. | ណែនាំបុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត នៅតាមគ្រឹះស្ថាន អ.ប.វ. ឱ្យគ្រប់គ្រងអារម្មណ៍ខ្លួនឯងឱ្យបានល្អ ដោយមិនត្រូវស្ថិតក្រោមទស្សនៈ "ការភ័យខ្លាច និងការរើសអើង" ដែលអាចធ្វើឱ្យស្ថានភាពកាន់តែធ្ងន់ធ្ងរ | |
| ៧.៦. | ណែនាំដល់បុគ្គលិក មន្ត្រីរាជការ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិតក្នុងគ្រឹះស្ថាន អ.ប.វ. ឬអ្នកដទៃទៀតដែលចូលទំនាក់ទំនងជាមួយគ្រឹះស្ថាន អ.ប.វ. ៖<br>- អនុវត្តការញើសសំបោរ ការខាកស្ដោះឱ្យត្រឹមត្រូវនៅបន្ទប់ទឹក ឬបង្គន់អនាម័យ ដោយមិនអនុញ្ញាតដាច់ខាតខាកស្ដោះ ឬញើសសំបោរ នៅក្នុងបន្ទប់រៀន បន្ទប់ប្រជុំ បណ្ណាល័យ បន្ទប់ពិសោធន៍ រោងជាង មជ្ឈមណ្ឌលធ្វើតេស្តសមត្ថភាព ឬក្នុងបរិវេណគ្រឹះស្ថាន អ.ប.វ.<br>- ធ្វើការខ្ទប់មាត់ និងច្រមុះនៅពេលក្អក ឬកណ្ដាស់ដោយប្រើគន្លាក់កែងដៃឬក្រដាសអនាម័យ រួចបោះចោលក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ<br>- មិនត្រូវប៉ះពាល់គ្នាដោយផ្ទាល់ដូចជា៖ ការចាប់ដៃ ឬប្រើប្រាស់របស់របរួមគ្នា និងត្រូវលើកកម្ពស់ការគោរពគ្នា ដោយការសំពះតាមទំនៀមទម្លាប់ខ្មែរ | |
| ៧.៧. | ណែនាំអ្នកបើកបររថយន្តដឹកសិក្ខាកាម សិស្ស និស្សិត ឱ្យពាក់ម៉ាសការពារជាប់ជាប្រចាំនៅពេលបើកបរ ត្រូវបើកបង្អួច ឬវាំងននឱ្យខ្យល់ចេញចូលបានល្អ ត្រូវអនុវត្តរក្សាគម្លាតកន្លែងអង្គុយដោយទុកចន្លោះ ១កៅអី | |
| ៧.៨. | ពិនិត្យកម្ដៅសិក្ខាកាម សិស្ស និស្សិត មុនអនុញ្ញាតឱ្យឡើងជិះរថយន្ត។ ប្រសិនបើឃើញថាមានកម្ដៅលើសពី ៣៧.៥អង្សាសេឡើងទៅ មិនត្រូវអនុញ្ញាតឱ្យឡើងជិះរថយន្តនោះទេ។ មុនពេលឡើងជិះរថយន្តត្រូវកំណត់ឱ្យសិក្ខាកាម សិស្ស និស្សិត និងអ្នកបើកបរលាងសម្អាតដៃនឹងទឹកអាល់កុល ឬទឹកដែលលាងដៃ រយៈពេល ២០វិនាទីជាមុនសិន | |

# ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ឈ្មោះគ្រឹះស្ថាន៖.....................................................

## បញ្ជីឈ្មោះបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស ដែលមានរោគសញ្ញាសង្ស័យ និងបានទៅធ្វើតេស្តរកកូវីដ-១៩

**ថ្ងៃទី......ខែ...........ឆ្នាំ........ វេលាម៉ោង..........នាទី នៅ................................................**

| ល.រ | ឈ្មោះ | ភេទ | តួនាទី | ឧបករណ៍ធ្វើតេស្ត | លទ្ធផល | លេខទូរសព្ទ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |

បញ្ចប់ត្រឹមលេខ៖..................ស្រី......នាក់។

*បញ្ជាក់៖ ការធ្វើតេស្តរកកូវីដ-១៩ ត្រូវធ្វើនៅទីតាំងស្របតាមនីតិវិធីជាធរមានរបស់ក្រសួងសុខាភិបាល ឬអាជ្ញាធរដែនដី។*

ថ្ងៃ............... ខែ...............ឆ្នាំ........ត្រីស័ក ព.ស.២៥៦៥

...................... ថ្ងៃទី....... ខែ......... ឆ្នាំ២០២១

**នាយក/នាយិកា**